# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ៥៧៤ កយ.កអជ/០៦

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
**ជម្រាបមក**

**លោកប្រធានតុលាការខេត្ត-ក្រុង**
**លោកព្រះរាជអាជ្ញារងអមតុលាការខេត្ត-ក្រុង**

**កម្មវត្ថុ:** អំពីករណីបទល្មើស និងចំណាត់ការរឿងក្តី ជួញដូរមនុស្សទៅតាមខេត្ត-ក្រុង នៃព្រះរាជាណាចក្រកម្ពុជា។

តបតាមកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបលោកជ្រាបថា ក្រោយពីក្រសួងយុត្តិធម៌ បានទទួលរបាយការណ៍ស្តីពីការជួញដូរមនុស្សទូទាំងប្រទេសរួចមកពិនិត្យឃើញថា បទល្មើសនេះមានការកើនឡើងជាលំដាប់ ហើយអាចនឹងបន្តកើនឡើងថែមទៀតផង ។ ករណីខាងលើនេះ បណ្តាលមកពីការធ្វេសប្រហែសពីមន្ត្រីអនុវត្តច្បាប់ដែលត្រូវធ្វើការទប់ស្កាត់ និងបំបាត់ទាំងស្រុងនូវបទល្មើស។ ដូច្នេះដើម្បីលើកស្ទួយកិត្យានុភាពរបស់ប្រទេស ចំពោះមតិអន្តរជាតិមួយវិញទៀតដើម្បីបន្តនយោបាយចតុកោណ និងវិធានការម៉ឺងម៉ាត់របស់សម្តេចនាយករដ្ឋមន្ត្រី ចំពោះការកែទម្រង់ប្រព័ន្ធយុត្តិធម៌ទាក់ទងនិងការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ជាពិសេស គឺបទល្មើសជួញដូរមនុស្សដែលជាគោលនយោបាយរបស់រដ្ឋាភិបាល ចំពោះម្ចាស់ជំនួយ និងដើម្បីធានាសណ្តាប់ធ្នាប់សង្គម សេចក្តីថ្លៃថ្នូសង្គម នឹងសុវត្ថិភាពរបស់ប្រជាពលរដ្ឋទូទាំងប្រទេសក្នុងការប្រកបការងាររបស់ខ្លួន ។

អាស្រ័យហេតុនេះ ក្រសួងយុត្តិធម៌ សូមឱ្យលោកប្រធានតុលាការ និងព្រះរាជអាជ្ញា យកចិត្តទុកដាក់ជាពិសេសចំពោះសំណុំរឿងជួញដូរមនុស្ស តាមខេត្ត-ក្រុង ដោយមានវិធានការច្បាស់លាស់ ត្រឹមត្រូវរិតតែមានប្រសិទ្ធិភាពខ្ពស់នូវគ្រប់ដំណាក់កាលតាំងពីមុនពេលប្រព្រឹត្តបទល្មើស និងរហូតដល់ពេលជំនុំជម្រះ ហើយចាត់តាំងឱ្យមានរបាយការណ៍ដោយឡែកជាប្រចាំខែ ដែលមានភ្ជាប់មកជាមួយនូវតារាងស្ថិតិបទល្មើសជួញដូរមនុស្ស ផ្ញើមកក្រសួងយុត្តិធម៌ ដើម្បីក្រសួងមានលទ្ធភាពពិនិត្យ និងតាមដានអំពីការវិវត្តន៍នបទល្មើសនេះជាចាំបាច់ ។

សូមលោកទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៦

**រដ្ឋមន្ត្រី**

**អង្គ វង្សវឌ្ឍានា**